ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ៧៧០ ព.ណ. [illegible]

# ប្រកាស
## ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិក

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម ។

## សម្រេច

**ប្រការ ១ :**

នាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិក ស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់របស់អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ មានមុខងារ និងភារកិច្ចដូចតទៅ៖

- ធ្វើសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មជាមួយប្រទេសនៅក្នុងតំបន់អនុតំបន់ និងទ្វេភាគីក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក
- ចូលរួមចរចាធ្វើសមាហរណកម្មសេដ្ឋកិច្ចរបស់កម្ពុជា រួមមាន ពាណិជ្ជកម្មសេវាពាណិជ្ជកម្មទំនិញ និងវិធានប្រភពដើមទំនិញ និងទទួលអនុវត្តគម្រោង



ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ:(៨៥៥)-២៣ ៨៦៦ ៤៦៩
Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA
Phone/Facsimile: (855)-23 866 469

អភិវឌ្ឍន៍សេដ្ឋកិច្ច និងពាណិជ្ជកម្មនៅក្នុងតំបន់អនុតំបន់និងទ្វេភាគី ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក

- សម្របសម្រួលការងារទូទៅ និងរៀបចំឯកសារនានាជូនថ្នាក់ដឹកនាំ សម្រាប់ចូលរួមកិច្ចប្រជុំថ្នាក់តំបន់ អនុតំបន់ និងទ្វេភាគី ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក
- ចូលរួមឬដឹកនាំគណៈកម្មាធិការ/គណៈកម្មាធិការចម្រុះសេដ្ឋកិច្ច-ពាណិជ្ជកម្ម ថ្នាក់តំបន់ អនុតំបន់ និងទ្វេភាគី ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក
- រៀបចំ និងសម្របសម្រួលអនុវត្តកាតព្វកិច្ច និងការសន្យារបស់កម្ពុជាថ្នាក់ តំបន់ អនុតំបន់ និងទ្វេភាគី ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក
- រៀបចំ និងសម្របសម្រួលការងារទាក់ទងនឹងកិច្ចព្រមព្រៀង និងពិធីសារពាក់ព័ន្ធអាស៊ាន និងជាមួយដៃគូអាស៊ាន ដើម្បីសុំសច្ចាប័ន និងជូនដំណឹងទៅលេខាធិការដ្ឋានអាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោក អំពីការចាប់ផ្តើមអនុវត្តកិច្ចព្រមព្រៀង និងពិធីសារទាំងនោះ
- ធ្វើជាលេខាធិការដ្ឋានឧត្តមមន្ត្រីសេដ្ឋកិច្ចអាស៊ាន រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន រដ្ឋមន្ត្រីក្រុមប្រឹក្សាសហគមន៍សេដ្ឋកិច្ចអាស៊ាន លេខាធិការដ្ឋានជាតិសហគមន៍សេដ្ឋកិច្ចអាស៊ាន លេខាធិការដ្ឋានតំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម និងលេខាធិការដ្ឋានអនុតំបន់ផ្សេងៗទៀត
- សម្របសម្រួល និងសហការជាមួយវិស័យឯកជន សង្គមស៊ីវិល អង្គការជាតិ និងអន្តរជាតិនានា លើវិស័យសេដ្ឋកិច្ច និងពាណិជ្ជកម្ម ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក
- រៀបចំផែនការ និងលើកគម្រោងសម្រាប់ស្នើសុំជំនួយបច្ចេកទេសពី រាជរដ្ឋាភិបាល តំបន់ អនុតំបន់ និងទ្វេភាគី និងដៃគូអភិវឌ្ឍន៍នានា សម្រាប់ធ្វើការពង្រឹងសមត្ថភាពស្ថាប័ន និងផ្សព្វផ្សាយ
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

**ប្រការ ២** :

នាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិកដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ។

**ប្រការ ៣** :

នាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិក មានការិយាល័យចំណុះចំនួន ០៥ គឺៈ

១- ការិយាល័យអាស៊ាន

២- ការិយាល័យដៃគូអាស៊ាន

៣- ការិយាល័យអនុតំបន់

៤- ការិយាល័យទ្វេភាគី

៥- ការិយាល័យផ្សព្វផ្សាយ និងរដ្ឋបាល

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ។

**ប្រការ ៤** :

ការិយាល័យអាស៊ាន មានភារកិច្ចៈ

- ធ្វើសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មជាមួយបណ្តាប្រទេសក្នុងតំបន់អាស៊ាន
- ចូលរួមចរចា និងសម្របសម្រួលធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជា រួមមានពាណិជ្ជកម្មសេវា ពាណិជ្ជកម្មទំនិញ និងវិធានប្រភពដើមទំនិញ និងទទួលអនុវត្តគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ច និងពាណិជ្ជកម្មក្នុងក្របខ័ណ្ឌអាស៊ាន
- សម្របសម្រួលការងារទូទៅ និងរៀបចំឯកសារនានា ជូនថ្នាក់ដឹកនាំសម្រាប់ចូលរួមកិច្ចប្រជុំក្នុងក្របខ័ណ្ឌអាស៊ាន
- រៀបចំ និងសម្របសម្រួលអនុវត្តកាតព្វកិច្ច និងការសន្យារបស់កម្ពុជា នៅក្នុងអាស៊ាន
- រៀបចំ និងសម្របសម្រួលការងារទាក់ទងនឹងកិច្ចព្រមព្រៀង និងពិធីសារពាក់ព័ន្ធអាស៊ាន ដើម្បីសុំសច្ចាប័ន និងជូនដំណឹងទៅលេខាធិការដ្ឋានអាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោក អំពីការចាប់ផ្តើមអនុវត្តកិច្ចព្រមព្រៀង និងពិធីសារទាំងនោះ
- សម្របសម្រួល និងសហការជាមួយវិស័យឯកជន សង្គមស៊ីវិល អង្គការជាតិ និងអន្តរជាតិនានា លើវិស័យសេដ្ឋកិច្ច និងពាណិជ្ជកម្ម ក្នុងតំបន់អាស៊ាន
- រៀបចំផែនការ និងលើកគម្រោងសម្រាប់ស្នើសុំជំនួយបច្ចេកទេសពី រាជរដ្ឋាភិបាលអាស៊ាន និងដៃគូអភិវឌ្ឍន៍នានា សម្រាប់ធ្វើការពង្រឹងសមត្ថភាពស្ថាប័ន និងផ្សព្វផ្សាយ
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

**ប្រការ ៥** :

ការិយាល័យដៃគូអាស៊ាន មានភារកិច្ចៈ

- ធ្វើសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មជាមួយបណ្តាប្រទេសដៃគូអាស៊ាន

- ចូលរួមចរចា និងសម្របសម្រួលការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជា ជាមួយបណ្តាប្រទេសដៃគូអាស៊ាន រួមមាន ពាណិជ្ជកម្មសេវា ពាណិជ្ជកម្មទំនិញ និងវិធានប្រភពដើមទំនិញ និងទទួលអនុវត្តគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ច និងពាណិជ្ជកម្ម
- សម្របសម្រួលការងារទូទៅ និងរៀបចំឯកសារនានា ជូនថ្នាក់ដឹកនាំ សម្រាប់ចូលរួមកិច្ចប្រជុំជាមួយដៃគូអាស៊ាន
- រៀបចំ និងសម្របសម្រួលអនុវត្តកាតព្វកិច្ច និងការសន្យារបស់កម្ពុជា ជាមួយដៃគូអាស៊ាន
- រៀបចំ និងសម្របសម្រួលការងារទាក់ទងនឹងកិច្ចព្រមព្រៀង និងពិធីសារពាក់ព័ន្ធជាមួយដៃគូអាស៊ាន ដើម្បីសុំសច្ចាប័ន និងជូនដំណឹងទៅលេខាធិការដ្ឋានអាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោក អំពីការចាប់ផ្តើមអនុវត្តកិច្ចព្រមព្រៀង និងពិធីសារទាំងនោះ
- សម្របសម្រួលនិងសហការជាមួយវិស័យឯកជន សង្គមស៊ីវិល អង្គការជាតិ និងអន្តរជាតិនានា លើវិស័យសេដ្ឋកិច្ច និងពាណិជ្ជកម្ម នៅក្នុងក្របខ័ណ្ឌដៃគូអាស៊ាន
- រៀបចំផែនការ និងលើកគម្រោងសុំជំនួយបច្ចេកទេសពី រាជរដ្ឋាភិបាលដៃគូអាស៊ាន និងដៃគូអភិវឌ្ឍន៍នានា សម្រាប់ធ្វើការពង្រឹងសមត្ថភាពស្ថាប័ន និងផ្សព្វផ្សាយ
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

**ប្រការ ៦** :

ការិយាល័យអនុតំបន់ មានភារកិច្ចៈ

- ធ្វើសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មនៅក្នុងក្របខ័ណ្ឌអនុតំបន់ដូចជា GMS, AMBDC, CLV, CLMV, ACMECS, AMEICC, CLT, MJ, LMI...
- ចូលរួមចរចា និងសម្របសម្រួលការធ្វើសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មកម្ពុជា និងទទួលអនុវត្តគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ច និងពាណិជ្ជកម្ម នៅក្នុងក្របខ័ណ្ឌអនុតំបន់
- សម្របសម្រួលការងារទូទៅ និងរៀបចំឯកសារនានាជូនថ្នាក់ដឹកនាំ សម្រាប់ចូលរួមកិច្ចប្រជុំនៅក្នុងក្របខ័ណ្ឌអនុតំបន់

- រៀបចំ និងសម្របសម្រួលអនុវត្តកាតព្វកិច្ច និងការសន្យាផ្នែកសេដ្ឋកិច្ច និងពាណិជ្ជកម្មរបស់កម្ពុជា នៅក្នុងក្របខ័ណ្ឌអនុតំបន់
- រៀបចំ និងសម្របសម្រួលការងារទាក់ទងនឹងកិច្ចព្រមព្រៀង និងពិធីសារពាក់ព័ន្ធនៅក្នុងក្របខ័ណ្ឌអនុតំបន់
- សម្របសម្រួលនិងសហការជាមួយវិស័យឯកជន សង្គមស៊ីវិល អង្គការជាតិ និងអន្តរជាតិនានា លើវិស័យសេដ្ឋកិច្ច និងពាណិជ្ជកម្ម នៅក្នុងក្របខ័ណ្ឌ អនុតំបន់
- រៀបចំផែនការ និងលើកគម្រោងសម្រាប់ស្នើសុំជំនួយបច្ចេកទេសពី រាជរដ្ឋាភិបាល ពីបណ្តាប្រទេសដៃគូ និងដៃគូអភិវឌ្ឍន៍នានា សម្រាប់ធ្វើការពង្រឹងសមត្ថភាពស្ថាប័ន និងផ្សព្វផ្សាយ
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

**ប្រការ ៧** :

ការិយាល័យទ្វេភាគី មានភារកិច្ចះ

- ធ្វើសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មទ្វេភាគីជាមួយបណ្តាប្រទេសនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក
- ចូលរួមចរចាបើកច្រកទីផ្សារ និងដោះស្រាយបញ្ហានានា ពាក់ព័ន្ធពាណិជ្ជកម្មទ្វេភាគីជាមួយបណ្តាប្រទេសនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក
- សម្របសម្រួលការងារទូទៅ និងរៀបចំឯកសារនានាជូនថ្នាក់ដឹកនាំ សម្រាប់ចូលរួមកិច្ចប្រជុំក្នុងក្របខ័ណ្ឌទ្វេភាគីនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក
- រៀបចំ និងសម្របសម្រួលអនុវត្តកាតព្វកិច្ច និងការសន្យារបស់កម្ពុជា ក្នុងក្របខ័ណ្ឌទ្វេភាគី ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក
- រៀបចំ និងសម្របសម្រួលការងារទាក់ទងនឹងកិច្ចព្រមព្រៀង និងពិធីសារពាក់ព័ន្ធទ្វេភាគីនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក
- សម្របសម្រួលនិងសហការជាមួយវិស័យឯកជន សង្គមស៊ីវិល អង្គការជាតិ និងអន្តរជាតិនានា លើវិស័យសេដ្ឋកិច្ច និងពាណិជ្ជកម្មទ្វេភាគី នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក
- រៀបចំផែនការ និងលើកគម្រោងសម្រាប់សុំជំនួយបច្ចេកទេសពី រាជរដ្ឋាភិបាល ប្រទេសដៃគូ និងដៃគូអភិវឌ្ឍន៍នានា សម្រាប់ធ្វើការពង្រឹងសមត្ថភាពស្ថាប័ន និងផ្សព្វផ្សាយ
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

**ប្រការ ៨** :

ការិយាល័យផ្សព្វផ្សាយ និងរដ្ឋបាលមានភារកិច្ចៈ

- សម្របសម្រួលកិច្ចការរដ្ឋបាលទូទៅរបស់នាយកដ្ឋាន
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គភាពចំណុះនាយកដ្ឋាន ក្រសួងពាណិជ្ជកម្ម ក្រសួង និងស្ថាប័ននានា ផ្នែកឯកជន សង្គមស៊ីវិល អង្គការជាតិ និងអន្តរជាតិ ដើម្បីផ្សព្វផ្សាយ
- សហការរៀបចំកិច្ចប្រជុំ ការផ្សព្វផ្សាយ និងបណ្តុះបណ្តាលក្នុងប្រទេសពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក
- រៀបចំគម្រោងថវិកាចំណាយរបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

**ប្រការ ៩** :

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានអង្គភាពចំណុះក្រសួង ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ២០១៤

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

ស៊ុន ចាន់ថុល

**កន្លែងទទួលៈ**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងមុខងារសាធារណៈ

-ដូចប្រការ ៩

-ឯកសារ-កាលប្បវត្តិ

# រចនាសម្ព័ន្ធនាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិក

- ប្រធាន នាយកដ្ឋាន
  - អនុប្រធាន នាយកដ្ឋាន
    - ការិយាល័យ អាស៊ាន
    - ការិយាល័យ ដៃគូអាស៊ាន
    - ការិយាល័យ អនុតំបន់
    - ការិយាល័យ ទ្វេភាគី
    - ការិយាល័យ ផ្សព្វផ្សាយ និងរដ្ឋបាល